# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ១៤១៥.ព្ររ.៣.២៦-៩៧

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**<u>សូមជម្រាបមក</u>**

**លោកប្រធានតុលាការខេត្ត-ក្រុង**
**លោកព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង**

**<u>កម្មវត្ថុ:</u>** អំពីសំណុំលិខិតពិនិត្យលទ្ធផលវិភាគកម្រិតជម្ងឺរបេង របស់ទណ្ឌិតដែលទាក់ទងនឹងការសុំដោះលែងដោយមានលក្ខខ័ណ្ឌ ឬអនុញ្ញាតឱ្យចេញទៅព្យាបាលនៅក្រៅមន្ទីរឃុំឃាំង ។

កន្លងមកក្រសួងតែងបានទទួលសំណើសុំការអនុញ្ញាតដើម្បីយកទណ្ឌិតទៅព្យាបាលនៅក្រៅមន្ទីរឃុំឃាំងឬក៏ធ្វើសំណុំបែបបទនៃការសុំដោះលែងទណ្ឌិតប្រភេទនេះដោយមានលក្ខខ័ណ្ឌដែលត្រូវអនុវត្តតាមមាត្រា ៧១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០-០៩-៩២ ។

ខ្ញុំសូមជម្រាបអស់លោកថា ជម្ងឺរបេង បច្ចុប្បន្ននេះមិនមែនជាជម្ងឺធ្ងន់ធ្ងរដូចជម្ងឺអេដស៍ទេ គេអាចព្យាបាលសះជាបានដោយងាយដោយថ្នាំព្យាបាលថ្មីៗនេះមានប្រសិទ្ធិភាពណាស់ ។ ប៉ុន្តែបញ្ហាមួយដែលឱ្យយើងចាប់អារម្មណ៍គឺជម្ងឺនេះឆ្លងទៅអ្នកនៅជាមួយគ្នា ហើយដោយសព្វថ្ងៃពន្ធនាគាររបស់យើងនៅមានការខ្វះខាតឱ្យទណ្ឌិតនៅរួមជាមួយគ្នា ក្រសួងយុត្តិធម៌បានគិតគូរដល់បញ្ហានេះពេញកម្រិត ។

អស់លោកអាចបញ្ជូនសំណូមពររបស់ប្រធានពន្ធនាគារ បន្ទាប់ពីលោកព្រះរាជអាជ្ញាបានពិនិត្យឃើញជម្ងឺរបស់ទណ្ឌិតកើតជម្ងឺរបេងជាក់ស្តែង ហើយក្រោយពីសុំឱ្យពេទ្យជំនាញបំពេញសំណុំលិខិតពេទ្យ ដោយមានលិខិតកោសល្យ វិច្ឆ័យបញ្ជាក់ច្បាស់លាស់ដូចមានណែនាំក្នុងលិខិតលេខ ៣៥៩ មរបហស.៩៧ ចុះថ្ងៃទី០៨-១០-៩៧ របស់គណៈកម្មាធិការមជ្ឈមណ្ឌលជាតិកំចាត់ជម្ងឺរបេង ដែលជូនភ្ជាប់មកជាមួយនេះស្រាប់ដើម្បីស្នើសុំដោះលែងឲ្យមានលក្ខខ័ណ្ឌ ។

ការដោះលែងឱ្យនៅក្រៅពន្ធនាគារដោយមានលក្ខខ័ណ្ឌនេះ គឺត្រូវបញ្ជាក់លើដីកាដោះលែងឱ្យទណ្ឌិតមកបង្ហាញខ្លួនមួយខែម្តង បើមានការមានៈមិនអនុវត្តតាមនេះទេ ត្រូវបញ្ចូលមកក្នុងពន្ធនាគារវិញ ។

សូមអស់លោកអនុវត្តតាមសេចក្តីណែនាំនេះឱ្យបានត្រឹមត្រូវបំផុត ។ ខ្ញុំសូមបញ្ជាក់ថាការសុំព្រលំ ឬការក្លែងបន្លំឈ្មោះអ្នកម្ចាស់កំហាក ឬអ្នកម្ចាស់ឈាម (បើជាជម្ងឺអេដ្រូស៍ ឬជម្ងឺគ្រុនចាញ់......។ ល ។ ) ដើម្បីដោះលែងមនុស្សទោសជាបទល្មើសដែលត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ហើយក្រសួងយុត្តិធម៌គ្មានសិទ្ធិអត់អោនឱ្យទេ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩៧

**រដ្ឋមន្ត្រី**

**ចែម ស្គួន**

<u>ចម្លងជូន</u>
-តុលាការខេត្ត-ក្រុង
-ព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង
-ដើម្បីជ្រាប